ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍

# ស្តីពី

# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែសីហា ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែសីហានេះ ការងារបង្កបង្កើនផលដំណាំរដូវវស្សាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ជាពិសេសស្រូវរដូវវស្សាសម្រេចបាន ២ ៦៨៧ ៣៨២ហ.ត ស្មើនឹង១០៣% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត។ វិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែសីហានេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់តាមរយៈការប្រជុំពីចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២១ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានគិតត្រឹមខែសីហា ឆ្នាំ២០២១នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៧២៦ ៤៨០ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១៦ ៣០៩ហ.ត ស្មើនឹង០,៦% និងដោយគ្រឿងយន្តចំនួន ២ ៧១០ ១៧១ហ.ត ស្មើនឹង៩៩,៤០%
- ផ្ទៃដីសាបសម្រេចបានចំនួន ១២ ៣៨៣ហ.ត តិចជាងឆ្នាំមុនចំនួន ២ ១៨០ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៦៨៧ ៣៨២ហ.ត ស្មើនឹង១០៣% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត លើសឆ្នាំមុន ១៣៩ ៩៦២ហ.ត។

### ១.២ ការប្រមូលផលស្រូវស្រាលរដូវវស្សា

ការប្រមូលផលស្រូវស្រាលសម្រេចចំនួន ៣៤២ ២៥៧ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ១ ៤២៨ ៨៥៥តោន លើសឆ្នាំមុនចំនួន ៦៨៨ ៥៤៨តោន និងទទួលទិន្នផលគិតជាមធ្យម ៤,១៧៥តោន/ហ.ត។

### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៥៣ ៣៩៩ហ.ត ស្មើនឹង៩៩,៤៧% នៃផែនការចំនួន ៥៣ ៦៨៦ហ.ត លើសឆ្នាំមុន ៩៧០ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៧៧៦ ០៥៦ហ.ត ស្មើនឹង៩៤,៦៤% នៃផែនការចំនួន ៨១៩ ៩៨៩ហ.ត លើសឆ្នាំមុន ១២ ២៤៥ហ.ត។

### ១.៤ ការនាំចេញផលិតផលកសិកម្ម

១.៤.១ ការនាំចេញអង្ករ

- ការនាំចេញអង្ករក្នុងខែសីហា ឆ្នាំ២០២១ មានចំនួន ៣៣ ៥៨២តោន កើនឡើងចំនួន ១១ ៤៥២តោន (៥១,៧៥%) បើធៀបនឹងខែសីហា ឆ្នាំ២០២០ ដែលមានចំនួន ២២ ១៣០តោន

- បរិមាណអង្ករនាំចេញក្នុងរយៈពេល៨ខែឆ្នាំ២០២១ មានចំនួន ៣៨៣ ៨៤៧តោន មានការថយចុះចំនួន ១០៤ ៧៥៦តោន (-២៣,៣៧%) បើធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល៨ខែឆ្នាំ២០២០ មានចំនួន ៤៤៨ ២០៣តោន

- ក្នុងរយៈពេល៨ខែឆ្នាំ២០២១ អង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន២២ប្រទេសមានបរិមាណសរុបចំនួន ៨៨ ២៧១តោន (ថយចុះចំនួន ៦១ ៥៧៧តោន ស្មើនឹង -៤១,០៩%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ១៦៥ ៦១២តោន (កើនឡើងចំនួន ៦ ៣៥៩តោន ស្មើនឹង ៣,៩៩%) ទិសដៅអាស៊ានចំនួន ៧ប្រទេស មានបរិមាណសរុបចំនួន ៣៥ ៥៥៣តោន(ថយចុះចំនួន ២៥ ៣៨០តោន ស្មើនឹង -៤១,៦៥%) និងទិសដៅដទៃទៀតចំនួន២២ប្រទេសមានបរិមាណសរុប ៥៤ ០១១តោន (ថយចុះចំនួន ២៤ ១៥៨តោន ស្មើនឹង -៣០,៩០%)

- ក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៥៩ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន១០ មានរហូតដល់ ២៨៧ ៩០៣តោន (៧២,១៨%) និងក្រុមហ៊ុន៤៩ដទៃទៀតបាននាំចេញត្រឹមតែ ៩៥ ៥៤៤តោន (២៧,៨២%)។

**១.៤.២ ការនាំចេញស្រូវ**

ក្នុងរយៈពេល៨ខែឆ្នាំ២០២១ ការនាំចេញស្រូវមានចំនួន ២ ៣៨៣ ១៥០តោន ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ១ ៥៦៤ ៩៥២,៥២តោន) កើនឡើងចំនួន ១ ១០១ ៤៣១តោន (៨៥,៩៣%) បើធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២០ ដែលមានចំនួន ១ ២៨១ ៧១៩តោន។

**១.៤.៣ ការនាំចេញកសិផលផ្សេងៗ**

ក្នុងរយៈពេល៨ខែ ឆ្នាំ២០២១ មានបរិមាណនាំចេញដោយធៀបនឹងរយៈពេល៨ខែ ឆ្នាំ២០២០៖

- ដំឡូងមីស្រស់មានចំនួន ៤៦៩ ៣០០តោន (ថយចុះចំនួន -៤,៦៦%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣៥៥ ៥៥០តោន និងប្រទេសថៃចំនួន ១១៣ ៧៥០តោន

- គ្រាប់ស្វាយចន្ទីមានចំនួន ៨៧៦ ៥២១,១៩តោន (កើនឡើងចំនួន ៣៤០,៦១%) នាំចេញទៅប្រទេសវៀតណាមចំនួន ៨៦៩ ៥៤០តោន ប្រទេសចិនចំនួន ៣ ៦៣៩,៥០តោន ប្រទេសថៃចំនួន ៣ ២៣០,៤០តោន ប្រទេសជប៉ុនចំនួន ៤៣,៦៧តោន ប្រទេសឥណ្ឌាចំនួន ១៧តោន ប្រទេសកូរ៉េចំនួន ១៦,៨៨តោន ប្រទេសអារ៉ាប់ចំនួន ១៤,៥១តោន ប្រទេសណេដឺឡែនចំនួន ៨,២១តោន ប្រទេសបង់ក្លាដែសចំនួន ៧តោន ប្រទេសឡាវចំនួន ៤តោន ប្រទេសតូហ្គោចំនួន ០,០១តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០១តោន

- គ្រាប់ពោតមានចំនួន ១៥២ ២០៤,១៩តោន (ថយចុះចំនួន -២១,៣៨%) នាំចេញទៅប្រទេសវៀតណាមចំនួន ១០៩ ០៤០តោន ប្រទេសថៃចំនួន ៤២ ៣៥០តោន កោះតៃវ៉ាន់ចំនួន ៧៥១,១៩តោន ប្រទេសបង់ក្លាដេសចំនួន ៤២តោន និងប្រទេសកូរ៉េចំនួន ២១តោន

- គ្រាប់សណ្តែកបាយមានចំនួន ២៣ ២៣០តោន (កើនឡើងចំនួន ៤៩៨,៧៧%) នាំចេញទៅប្រទេសវៀតណាម

- គ្រាប់សណ្តែកសៀងមានចំនួន ១៩ ៨៨០,០៤តោន (កើនឡើងចំនួន ១០០%) នាំចេញទៅប្រទេសវៀតណាមចំនួន ១១ ៩៣០តោន ប្រទេសថៃចំនួន ៧ ៩៥០តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០៤តោន

- ផ្លែចេកស្រស់មានចំនួន ៣១០ ១៨៣,២៨តោន (កើនឡើងចំនួន ៥៦,៧៩%) នាំចេញទៅប្រទេសចិនចំនួន ២៧២ ០២៣,៩៥តោន ប្រទេសវៀតណាមចំនួន ៣៧ ១៤៥,៣៣តោន ប្រទេសជប៉ុនចំនួន ៥៣៣,៥២តោន និងប្រទេសសិង្ហបុរីចំនួន ៤៨០,៤៨តោន

- ផ្លែក្រូចថ្លុងមានចំនួន ៣៤ ៩១៨,៤៤តោន (កើនឡើងចំនួន ១៣០,៤៨%) នាំចេញទៅប្រទេសថៃចំនួន ៣៤ ៨៥៤តោន និងប្រទេសវៀតណាមចំនួន ៦៤,៤៤តោន

- ផ្លែស្វាយស្រស់មានចំនួន ១៦៣ ៨២៨,៥៥តោន (កើនឡើងចំនួន ២៥១,០៣%) នាំចេញទៅប្រទេសវៀតណាមចំនួន ១៤០ ៩៥៦,៦៨តោន ប្រទេសថៃចំនួន ២២ ៤៦៩,២៨តោន ប្រទេសចិនចំនួន ២១១,២២តោន ប្រទេសកូរ៉េចំនួន ១២៤,៣៨តោន ទីក្រុងហុងកុងចំនួន ៥០,៧៨តោន ប្រទេសសិង្ហបុរីចំនួន ១៦,២០តោន និងប្រទេសគុយវ៉ែតចំនួន ០,០១តោន

- ដូងប្រេងមានចំនួន ៣៧ ៨៣៦,៦៩តោន (កើនឡើងចំនួន ៤,៣២%) នាំចេញទៅប្រទេសឥណ្ឌាចំនួន ៣០ ៦១៦,៦៩តោន និងប្រទេសម៉ាឡេស៊ីចំនួន ៧ ២២០តោន

- ម្រេចមានចំនួន ២៤ ៨៤៧,៤៥តោន (កើនឡើងចំនួន ៥៥១,៧៣%) នាំចេញទៅប្រទេសវៀតណាមចំនួន ២៤ ៤៧៦,៦៨តោន ប្រទេសអាល្លឺម៉ង់ចំនួន ២៤៧តោន ប្រទេសឥណ្ឌាចំនួន ៤២តោន ប្រទេសបារាំងចំនួន ២០,១៨តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ១៥,៩៨តោន កោះតៃវ៉ាន់ចំនួន ១៥,០៤តោន ប្រទេសប៉ូឡូញចំនួន ៧,០៩តោន សាធារណរដ្ឋឆែក

ចំនួន ៦,១០តោន ប្រទេសជប៉ុនចំនួន ៣,៣០តោន ប្រទេសកូរ៉េចំនួន ៣,២៥តោន ប្រទេសរុស្ស៊ីចំនួន ២,៤០តោន ប្រទេសសិង្ហបុរីចំនួន ១,៩៧តោន សហរដ្ឋអាមេរិកចំនួន ១,៧៥តោន ប្រទេសស៊ុយអ៊ែតចំនួន ១,២៩តោន ចក្រភពអង់គ្លេសចំនួន ១,២៤តោន ប្រទេសអូស្ត្រាលីចំនួន ០,៩០តោន ប្រទេសស្វីសចំនួន ០,៥៦តោន ប្រទេសកាណាដាចំនួន ០,៥២តោន ប្រទេសកាហ្សាក់ស្ថានចំនួន ០,១៩តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០១តោន

- ថ្នាំជក់មានចំនួន ១ ៨៩៩,៧៥តោន (ថយចុះចំនួន -៦២,១៨%) នាំចេញទៅប្រទេសវៀតណាម ១ ៨៦០តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ១៩,៨២តោន ប្រទេសហុងគ្រីចំនួន ១៩,៨០តោន ប្រទេសចិនចំនួន ០,១០តោន ប្រទេសឥណ្ឌូនេស៊ីចំនួន ០,០២តោន ប្រទេសសិង្ហបុរីចំនួន ០,០១តោន និងប្រទេសអាល្លឺម៉ង់ចំនួន ០,០០១តោន

- បន្លែចម្រុះមានចំនួន ៦៦,៥៣តោន (ថយចុះចំនួន -១៥,៦២%) នាំចេញទៅប្រទេសបារាំង

- ម្ទេសស្រស់មានចំនួន ៧១ ២៩៧,១២តោន (កើនឡើងចំនួន ៤៣,៣៨%) នាំចេញទៅប្រទេសថៃចំនួន ៧១ ២៩៧,១២តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០០២តោន

- ម្ទេសក្រៀមមានចំនួន ១ ៣២០,២៣តោន (ថយចុះចំនួន -១១,៩៨%) នាំចេញទៅប្រទេសថៃចំនួន ១ ៣២០តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ០,២១តោន ប្រទេសកូរ៉េចំនួន ០,០១តោន និងប្រទេសកាណាដាចំនួន ០,០១តោន។

## ២ ផ្នែកផលិតកម្មកៅស៊ូ (ខែកក្កដា)

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ១៦០ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៨ ៥៤៦ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩៤ ៤៥៤ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦១ ១៦០ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១៤ ៣១៩ហ.ត ស្មើនឹង៧៨% និងផ្ទៃដីថែទាំចំនួន ៨៩ ៨៤១ហ.ត ស្មើនឹង២២%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូចំនួន ៣១ ៤៦៧តោន កើនឡើងចំនួន ៧៤២តោន ស្មើនឹង២% ធៀបខែមុន និងកើនឡើងចំនួន ៤ ៣៥២តោន ស្មើនឹង១៦% ធៀបខែកក្កដា ឆ្នាំ២០២០

- ផលិតផលឈើកៅស៊ូចំនួន ១០០ម៣ ថយចុះចំនួន ៣៨៥ម៣ ស្មើនឹង៧៩% ធៀបខែមុន។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណជ័រកៅស៊ូបញ្ចេញលក់ចំនួន ៣០ ៦៨២តោន កើនឡើងចំនួន ១ ៧៥១តោន ស្មើនឹង៦% ធៀបខែមុន និងកើនឡើងចំនួន ២ ៣៥៩តោន ស្មើនឹង៨% ធៀបខែកក្កដា ឆ្នាំ២០២០

- បរិមាណបញ្ចេញលក់ឈើកៅស៊ូចំនួន ៤១១ម៣ ថយចុះចំនួន ៧៤ម៣ ស្មើនឹង១៥% ធៀបខែមុន។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃជ័រកៅស៊ូលក់មធ្យមក្នុងខែកក្កដាគឺ១ ៦១៥ដុល្លារ/តោន ថយចុះចំនួន ១២០ដុល្លារ/តោន ស្មើនឹង៦,៩០% ធៀបខែមុន និងកើនឡើងចំនួន ៣៧៦ដុល្លារ/តោន ស្មើនឹង៣០% ធៀបខែកក្កដា ឆ្នាំ២០២០

- តម្លៃឈើកៅស៊ូលក់មធ្យមក្នុងខែកក្កដាគឺ៣១៧ដុល្លារ/ម៣

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការក្នុងខែមិថុនាគឺទឹកជ័រ (DRC ១០០%) មានការប្រែប្រួលពី ៥ ៧០០៛/គ.ក្រ ដល់ ៦ ០០០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ៥១៣៛/គ.ក្រ ដល់ ៣ ២៦៣៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្តជូនក្រុមហ៊ុនក្រុមហ៊ុន អ៊ូ ជី សាន អិល អេស គ្រុប និងក្រុមហ៊ុន ហួរ លីង(ខេមបូឌា) អ៊ិនធើណេសិនណល អ៊ិនសឺរេន នៅខេត្តមណ្ឌលគិរីមានរណារយន្តចំនួន ១៥គ្រឿង និងយានយន្តចំនួន ១៧គ្រឿង និងផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនអ្នកស្នើសុំចំនួន ១នាក់ មានជ័រទឹកចំនួន ១០០តោន

- ធ្វើសារពើភណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើ ជូនក្រុមហ៊ុន ខេមបូឌា ដោន ផ្លេនថេសិន អិលធីឌី ស្ថិតនៅខេត្តព្រះវិហារ។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- សិក្សា និងអង្កេតសត្វព្រៃផ្ទាល់កំពុងរស់នៅ និងបន្តពូជនៅក្នុងសហគមន៍ព្រៃឈើវាលកន្សែងស្ថិតក្នុងស្រុកឆ្លូង ខេត្តក្រចេះ

- សហការជាមួយអង្គការ WCS ដើម្បីចុះពិនិត្យអង្កេត និងការពារសំបុកពងកូនសត្វត្រយ៉ងយក្សដែលទើបនឹងញាស់ចំនួន ២សំបុកក្នុងឆ្នាំ២០២១ និងចុះប្រមូលសំណាកសត្វចៃតឹកកែ និងចៃចេញពីសត្វស្រុក និងសត្វព្រៃស្ថិតខេត្តព្រះវិហារ។ ព្រមទាំងចុះពង្រឹងការថែរក្សាសត្វព្រៃចំនួន ១លើកនៅសហគមន៍ព្រៃឈើប្រាំបីមុម ខេត្តកំពង់ស្ពឺ

- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃឆ្លងទៅកាន់មាត់ច្រកអន្តរជាតិសម្រាប់នាំចេញចំនួន ៧ច្បាប់ មានសត្វស្វាក្ដាមសរុបចំនួន ៤ ០០០ក្បាល និងលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ៣ច្បាប់សម្រាប់ការថែរក្សាសត្វត្រចៀកកាំ និងថែរក្សាសត្វព្រៃមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧កំពុងដំណើរការកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្ដាមយកកូននាំចេញមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង មានស្វាក្ដាមចំនួន ៩១ ១៤៨ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៥ ៦០៤ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៦០៧ក្បាល(បក្សីចំនួន ៥៨ប្រភេទ ថនិកសត្វចំនួន ៤៥ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វព្រៃថ្មីចំនួន ៦៧ក្បាល ព្យាបាលចំនួន ៣០ក្បាល និងស្ដារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងសត្វព្រៃគ្រប់ប្រភេទទៅព្រៃធម្មជាតិចំនួន ២៧ក្បាល

- ក្រុមល្បាតសហគមន៍ចំនួន ៣០នាក់ ដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺៈ អារ៉ែង ឆាយរាប តំបន់ស្ដារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ជួសជុលផ្លូវដោយក្រាលក្រួសក្រហមប្រវែង ៧០០ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ ០,៨ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- ដឹកប្រឡាយការពារចម្ការគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំប្រវែង១ ៥០០ម៉ែត្រ

- ចុះពិនិត្យទីតាំងសម្រាប់ចុះបញ្ជីព្រៃឯកជនលើចំនួន ៣កន្លែង ស្ថិតនៅខេត្តកំពត និងខេត្តកោះកុងលើផ្ទៃដីទំហំ ៣៥០ហ.ត មានឈើបេង គ្រញូង ធ្នង់ គីនីន និងចន្ទន៍ក្រស្នាសរុបចំនួន ១ ០៣០ ០០០ដើម

- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ៨២២ហ.ត ក្នុងនោះចម្ការពូជឈើទំហំ៩៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ៤៤ហ.ត ចម្ការឈើដាំទំហំ៦៥៤ហ.ត និងចម្ការរុក្ខទិវា ៩កក្កដា ទំហំ៣០ហ.ត ស្ថិតខេត្តកំពត កណ្ដាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- ដាំឈើជាចម្ការថ្មីទំហំ២០ហ.ត នៅស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំ

- បណ្ដុះកូនឈើគ្រប់ប្រភេទចំនួន ៧ ៦៣០ដើម ដោយថ្នាលបណ្ដុះកូនឈើតាមបណ្ដាខណ្ឌរដ្ឋបាល ព្រៃឈើរាជធានី-ខេត្ត និងចែកចាយកូនឈើចំនួន ៨០ ៩៤៥ដើម ក្នុងនោះថ្នាលបណ្ដុះកូនឈើតាម បណ្ដាខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ២៩ ៧៨៥ដើម និងថ្នាលបណ្ដុះកូនឈើចំនួន ៥១ ១៦០ដើម។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើចំនួន ៦៣ករណី

- វត្ថុតាងបទល្មើសព្រៃឈើចាប់ឃាត់ និងដកហូតរួមមានឈើអារសរុបចំនួន ៩២ម៣ ផ្ទៃដីព្រៃឈើកាប់រានទំហំ ៦៣ហ.ត (ខេត្តព្រៃវែង ក្រចេះ ស្ទឹងត្រែង និងខេត្តមណ្ឌលគិរី) វត្ថុតាងសត្វព្រៃ ចាប់ឃាត់ចំនួន ១ករណី (ខេត្តព្រះសីហនុ) និងអនុផលព្រៃឈើ ព្រមទាំងសម្ភារមួយចំនួនទៀត

- វត្ថុតាងសត្វព្រៃ និងសំណាកសត្វព្រៃប្រមូលតាមរយៈការប្រគល់-ទទួលចំនួន ៣៩ករណី ធ្វើកិច្ចសន្យា ចំនួន ១២ករណី និងដកហូតចំនួន ១១ករណី។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែ មួយ) ចំនួន ១កន្លែងនៅខេត្តព្រះវិហារ និងពន្យារសុពលភាពចំនួន ១កន្លែងនៅខេត្តកំពង់ធំ

- ពិនិត្យករណីសំណើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ១កន្លែងនៅខេត្តព្រះវិហារ និងពន្យារសុពលភាពចំនួន ២កន្លែងនៅខេត្តស្ទឹងត្រែង ព្រមទាំងពិនិត្យសំណើសិក្សាអត្រាកែច្នៃកូនឈើទំហំគល់ ១៥-៣០ស.ម ចំនួន ១ក្រុមហ៊ុន

- ក្រុមហ៊ុនចំនួន១នាំចេញផលិតផលរានទេវតា ឈើកែច្នៃ ទៅក្រៅប្រទេសមានចំនួន ២៦ម៣ និងក្រុមហ៊ុនចំនួន១នាំចូលឈើកែច្នៃមានបរិមាណចំនួន ៥៧ម៣

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន២មានឈើកែច្នៃចំនួន ៥៥ម៣ និងឫស្សីកែច្នៃចំនួន ១៩តោន។

**៣.៧ ការងារចំណូលព្រៃឈើ**

- ប្រមូលចំណូលសរុប ៣២៦ ៣៨៨ ១៧០រៀល និង៥២២ ៧៧៥,៧២ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

**៤.២ ការងារសុខភាពសត្វ**

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ២៤ករណី។ រាជធានី-ខេត្តចំនួន ២៤ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៧ ៤១៨លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស**

  ចុះណែនាំកសិករ និងអ្នកពាក់ព័ន្ធស្តីពីជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន២។
- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ។

**៤.៣ ការងារស្រាវជ្រាវ**

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៧ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ២ ៤៧៨វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) និងជំងឺដុំពកស្បែកគោ ក្របី (LSD)។

## ៥ ផ្នែកជលផល

**៥.១ អាជីវកម្មនេសាទ**

៥.១.១ នេសាទទឹកសាប

- ដាយត្រីអនុវត្តបញ្ចប់ត្រឹមចំនួន ១ ៣១០តោន ស្មើនឹង១១,៩១% នៃផែនការចំនួន ១១ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២០ ថយចុះចំនួន ១៩០តោន

- នេសាទគ្រួសារដែននេសាទបានចំនួន ២០ ៥០០តោន សរុបរយៈពេល៨ខែចំនួន ១៧៣ ៩០០តោន ស្មើនឹង ៥៧,៩៧% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២០ កើនឡើងចំនួន ៣ ៥០០តោន

- នេសាទគ្រួសារតាមវាលស្រែបានចំនួន ៤ ២០០តោន សរុបរយៈពេល៨ខែចំនួន ២៩ ៥០០តោន ស្មើនឹង២១,០៧% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២០ ថយចុះចំនួន ២១ ៥០០តោន។

**៥.១.២ នេសាទសមុទ្រ**

បានចំនួន ៩ ៤០០តោន សរុបរយៈពេល៨ខែចំនួន ៧៧ ៣០០តោន ស្មើនឹង៥៩,៤៦% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២០ ថយចុះចំនួន ៣០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាបានចំនួន ៣ ៧៥៧តោន សរុបរយៈពេល៨ខែចំនួន ១៥១ ១៦៩តោន ស្មើនឹង៣១,៤៣% នៃផែនការចំនួន ៤៨១ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២០ ថយចុះចំនួន ៩២ ២៣១តោន

- ការចិញ្ចឹមក្រពើបានចំនួន ៥៥ ៤០០ក្បាល សរុបរយៈពេល៨ខែចំនួន ១៩៧ ៨០០ក្បាល ស្មើនឹង៥៩,៩៤% នៃផែនការចំនួន ៣៣០ ០០០ក្បាល ប្រៀបធៀបខែសីហា ឆ្នាំ២០២០ ថយចុះចំនួន ២៣ ៤៩០ក្បាល

- ការភ្ញាស់កូនត្រីពូជបានចំនួន ៣៦ ២៤៨ ០០០កូន សរុបរយៈពេល៨ខែចំនួន ១៥៨ ៧៤៨ ០០០កូន ស្មើនឹង៥៨,៨០% នៃផែនការចំនួន ២៧០ ០០០ ០០០កូន ប្រៀបធៀបខែសីហា ឆ្នាំ២០២០ កើនឡើងចំនួនប្រមាណ ១៦ ៩៤៨ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបបានចំនួន ៦ ៥៤០តោន សរុបរយៈពេល៨ខែចំនួន ៣៨ ៤៥០តោន ស្មើនឹង៤៨,០៦% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២០ ថយចុះចំនួន ១ ៩០០តោន

- ផលនេសាទសមុទ្របានចំនួន ៨១០តោន សរុបរយៈពេល៨ខែចំនួន ៧ ៧៧០តោន ស្មើនឹង៦៤,៧៥% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២០ កើនឡើងចំនួន ២០តោន

- ការផលិតទឹកត្រីបានចំនួន ១ ៧០៤ ០០០លីត្រ សរុបរយៈពេល៨ខែចំនួន ៣៨ ៤៦២ ០០០លីត្រ ស្មើនឹង ៦៩,៩៣% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបខែសីហា ឆ្នាំ២០២០ ថយចុះចំនួន ២ ០៥០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ២៣៤ករណី ប្រៀបធៀបខែសីហា ឆ្នាំ២០២០ កើនឡើងចំនួន ៤៩ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២៣៤ករណី និងសមុទ្រពុំមាន។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ៤០៨តោន សរុបរយៈពេល៨ខែចំនួន ២ ៦៦៧តោន ស្មើនឹង៣៣,៣៤% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២០ កើនឡើងចំនួន ១ ៣៤៦តោន

- ផលនេសាទកែច្នៃនាំចេញពុំមាន សរុបរយៈពេល៨ខែចំនួន ១៥០តោន ស្មើនឹង៧,៥០% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបខែសីហា ឆ្នាំ២០២០ ថយចុះចំនួន ៨២តោន។

### ៥.៦ ការប្រមូលថវិកាសេវាជលផល

- ចំណូលចំនួន ២៣ ៥៦៦ ៣០០រៀល សរុបចំណូលរយៈពេល៧ខែចំនួន ៤៤៨ ៤៩២ ៤២៨រៀល ស្មើនឹង ១២៥,០៧% នៃផែនការចំនួន ៣៥៨ ៦០០ ០០០រៀល ប្រៀបធៀបខែសីហា ឆ្នាំ២០២០ ថយចុះចំនួន ៦ ៩០៥ ៩៣២រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- ចុះពង្រឹង និងត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផល ផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាតនៅខេត្តត្បូងឃ្មុំ ព្រៃវែង កណ្ដាល តាកែវ កំពត ស្វាយរៀង និងរាជធានីភ្នំពេញ

- ចុះត្រួតពិនិត្យការអនុវត្តលិខិតកែលម្អលេខ ១៥៣២កសក.អធ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ នៅខេត្តសៀមរាប

- ចុះស្រាវជ្រាវលើករណីបណ្ដឹងអនាមិកស្ដីពីភាពមិនប្រក្រតីក្នុងកិច្ចលទ្ធកម្មជ្រើសរើសទីប្រឹក្សាបច្ចេកទេសក្រោមកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

- ការទទួលពាក្យបណ្ដឹងតាមរយៈប្រអប់សំបុត្រ និងតាមរយៈប្រព័ន្ធអ៊ិនធើណេតចំនួន ២ករណី

- ស្រាវជ្រាវព័ត៌មានតាមបណ្ដាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៨០ករណី លើវិស័យព្រៃឈើ១១ករណី ផលផល១៨ករណី សុខភាពសត្វនិងផលិតកម្មសត្វ១៥ករណី និងវិស័យផ្សេងៗ៣៦ករណី។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៧០០ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២៦៤ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣២៥ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១១១ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៩០៣ច្បាប់ ចេញប្រកាស សេចក្ដីសម្រេច និងសារាចរចំនួន ៣៣ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១៥ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្ដាប់ឱ្យបាននូវរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្ដាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៥ ៨២០នាក់ (ស្រី១ ៤១៤នាក់ ស្មើនឹង២៤,២៥%) រួមមាន៖
  + អង្គភាពថ្នាក់កណ្ដាលចំនួន ២ ៩១៨នាក់ (ស្រី៨២៤នាក់ ស្មើនឹង២៨,២៣%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩០២នាក់ (ស្រី៥៩០នាក់ ស្មើនឹង២០,៣៣%)

- រៀបចំប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន ២នាក់ ផ្ទេរចូលក្នុងក្រសួងចំនួន ៤នាក់ និងផ្ទេរផ្ទៃក្នុងក្រសួងចំនួន ៥នាក់

- រៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ២នាក់ ក្នុងនោះ ច្បាប់ឈប់សម្រាករយៈពេលខ្លីចំនួន ១នាក់ និងច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ១នាក់

- រៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យចូលបម្រើការងារវិញចំនួន ៣នាក់

- រៀបចំការបណ្ដុះបណ្ដាលក្នុង និងក្រៅប្រទេសសរុបចំនួន ១០២នាក់ (ស្រី៤៤នាក់) ក្នុងនោះ៖
  + ការបណ្ដុះបណ្ដាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមចំនួន ៩២នាក់ (ស្រី៣៩នាក់)
  + ការបណ្ដុះបណ្ដាលក្រៅប្រទេសរយៈពេលខ្លី និងមធ្យមតាមរយៈប្រព័ន្ធ online ចំនួន ១០នាក់ (ស្រី៥នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- ចូលរួមសហការជាមួយក្រុមការងារបច្ចេកទេសនៃអគ្គនាយកដ្ឋានកសិកម្មសិក្សាអំពីខ្សែច្រវាក់ផលិតកម្មដំណាំប៉េងប៉ោះ ល្ង និងដំឡូងជ្វា

- ចុះពិនិត្យ និងផ្ទៀងផ្ទាត់សន្និធិស្រូវពូជនៅខេត្តមណ្ឌលគិរី និងខេត្តស្ទឹងត្រែង

- រៀបចំពិនិត្យ និងបញ្ជូនវិធានការគោលនយោបាយជំរុញវារីវប្បកម្មកម្ពុជាឆ្នាំ២០២១-២០២៣

- រៀបចំ និងសម្របសម្រួលស្ដីពីសំណើសុំផ្ដល់ទិន្នន័យអុស ធ្យូង ជីវម៉ាស់ និងចំនួនគ្រឿងយន្តកសិកម្ម សម្រាប់ឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩

- ពិនិត្យ និងរៀបចំផ្ដល់ធាតុចូលរបាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣

- ធ្វើការណែនាំ និងធ្វើអង្កេតស្ទង់ទិន្នផលស្រូវស្រាលដើមរដូវវស្សាឆ្នាំ២០២១-២០២២ ដោយសហការជាមួយមន្ត្រីស្ថិតិថ្នាក់ខេត្ត និងស្រុកនៅខេត្តមណ្ឌលគិរី និងខេត្តតាកែវ

- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្ដាហ៍៣ដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយរៀងរាល់ថ្ងៃព្រហស្បតិ៍នៃសប្ដាហ៍តាមបណ្ដាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផល នៅតាមបណ្ដារាជធានី-ខេត្តទាំង២៥

- ចុះតាមដាន និងវាយតម្លៃការអនុវត្តសកម្មភាពក្នុងក្របខ័ណ្ឌថវិកាកម្មវិធីនៅខេត្តកំពត តាកែវ ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី និងខេត្តរតនគិរី។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- ចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន ១៦ ៣០៧ ៩៨៩ ៥៦២រៀល

- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ៦ ៨១៥ ០៧៥ ១៥៣រៀល

- រៀបចំសំណើសុំគោលការណ៍ធានាចំណាយឥណទានថវិកាជំពូក២១ ចំនួន ៨ ៨៦២ ១៥៨ ០០០រៀល និងថវិកាបុរេប្រទានចំនួន៤០%សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅតាមបណ្ដាសហគមន៍កសិកម្មក្នុងខេត្តគោលដៅសម្រាប់ឆ្នាំ២០២១

- រៀបចំសំណើសុំថវិកាចំនួន ១០៩ ៦៩៨,២៤ដុល្លារអាមេរិក ដើម្បីបំពេញឡើងវិញចូលគណនីគម្រោងរបៀងអភិរក្សជីវចម្រុះមហាអនុតំបន់មេគង្គក្រោមហិរញ្ញប្បទានឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

- ទទួលថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ៤ក្រុមហ៊ុន

- រៀបចំលិខិតជូនដំណឹងស្ដីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន ១៤ក្រុមហ៊ុន

- ចុះពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីគណនេយ្យឆ្នាំ២០២០ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ

- ចូលរួមប្រជុំពិនិត្យ និងវាយតម្លៃផលឈើដាំដែលមានទីតាំងដីនៅស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ និងស្រុកសៀមបូក ខេត្តស្ទឹងត្រែង

- ទទួលឥណទានធានាចំណាយចំនួន៤គម្រោង និងរៀបចំឯកសារសុំគោលការណ៍អនុវត្តវិធីសាស្ត្រលទ្ធកម្មដោយឡែកទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីដំណើរការអនុវត្តនូវកិច្ចលទ្ធកម្ម

- ចុះពិនិត្យ និងតាមដានការអនុវត្តកិច្ចសន្យាលេខ២៦/២០កសក.លក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ស្ដីពីការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅតាមបណ្ដាសហគមន៍នៅខេត្តកំពង់ចាម ព្រៃវែង និងខេត្តកំពង់ឆ្នាំងដែលអនុវត្តដោយនាយកដ្ឋានវិស្វកម្មកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម

- ចុះពិនិត្យផ្ទេរផ្គងតារាងប្រៀបធៀបកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២០ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម ត្បូងឃ្មុំ និងខេត្តកំពង់ស្ពឺ។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- ធ្វើផែនការរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រប់គ្រងឆ្នាំ២០២២

- ធ្វើគម្រោងថវិកាសម្រាប់គ្រប់គ្រងឆ្នាំ២០២២

- ធ្វើគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ២០២២

- ចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ចំនួន ៥អង្គភាពគឺ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ ខេត្តកំពង់ចាម តាកែវ អគ្គនាយកដ្ឋានកសិកម្ម និងគម្រោងការគ្រប់គ្រងធនធានជលផលភូមិភាគឥសាន្ត។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ចូលរួមកិច្ចប្រជុំតាមប្រព័ន្ធវីដេអូពីចម្ងាយ៣លើក ក្រោមក្របខ័ណ្ឌអាស៊ាន

- បានសម្របសម្រួលកិច្ចប្រជុំចំនួន ៦លើកលើការងារក្នុងប្រទេស

- សម្របសម្រួលកិច្ចការងារជាមួយអង្គការ Heifer ចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងលើកកម្ពស់ផលិតផលមាន់ស្រែខ្មែរសម្រាប់មោទកភាពជាតិខ្មែរ

- សម្របសម្រួលកិច្ចការងារជាមួយអង្គការគោសប្បុរសដើម្បីកម្ពុជាចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងគោសប្បុរសដើម្បីកម្ពុជា។

**១៣ ផ្នែកនីតិកម្មកសិកម្ម**

**១៣.១ ការិយាល័យអាជីវកម្មជី-ថ្នាំកសិកម្ម**

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣១ក្រុមហ៊ុន សរុបចំនួន ៣៦៧មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២១ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៨ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ និងវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ១ក្រុមហ៊ុន។

**១៣.២ ការិយាល័យមន្ទីរពិសោធន៍**

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៧ក្រុមហ៊ុន សរុបចំនួន ៣៣សំណាក។

**១៣.៣ ការិយាល័យអភិវឌ្ឍបទដ្ឋានគតិយុត្ត**

បានពិនិត្យលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗចំនួន ២ករណី។

**១៣.៤ ការិយាល័យអនុវត្តច្បាប់**

- ចុះពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១២ក្រុមហ៊ុន
- ចុះពិនិត្យការស្នើសុំចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្ម និងលាយផ្សំវេចខ្ចប់ជាថ្មីចំនួន ៤ក្រុមហ៊ុន។

**១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម**

- ធ្វើការតាមដាន និងថែទាំគេហទំព័ររបស់ក្រសួង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឲ្យដំណើរការល្អរលូន
- តាមដានទិន្នន័យដែលផ្ទុកនៅលើ cloud server នៃគេហទំព័រទាំង៤១
- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់អង្គភាពថ្នាក់កណ្តាលលើគេហទំព័រចំនួនផុស៦ព័ត៌មាន
- តាមដាន និងថែទាំម៉ាស៊ីន Firewall ដើម្បីទប់ស្កាត់ការចូលពីអ្នកខាងក្រៅ (Hacker)
- ចុះថតផលិតវីដេអូស្តីពីបទពិសោធន៍ជោគជ័យរបស់កសិករដាំធុរេនក្នុងខេត្តមណ្ឌលគិរី
- ទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តីទទួលពីនាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗ ចំនួន ៥ក្បាល/ច្បាប់
- ចុះបណ្តុះបណ្តាលការប្រើប្រាស់ និងផ្សព្វផ្សាយកម្មវិធីស្មាតហ្វូន (Mobile App) និងគេហទំព័រ (website) របស់បណ្ណាល័យកសិកម្ម និងពិនិត្យអំពីការរៀបចំបណ្ណាល័យសម្រាប់តម្កល់ឯកសាររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ចាម។

**១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- ចុះទៅថត Video បទយកការណ៍ស្តីពីភាពជោគជ័យនៃការដាំដំណាំបន្លែក្នុងផ្ទះសំណាញ់នៅខេត្តកណ្តាល
- ចាក់ផ្សាយឡើងវិញស្តីពីវេទិកាស្វែងយល់ពីកសិកម្មចំនួន ១ប្រធានបទ
- ចាក់ផ្សាយឡើងវិញស្តីពីនាទីចុះស្រែជាមួយកសិករចំនួន ១ប្រធានបទ
- បញ្ជូនអត្ថបទបច្ចេកទេសកសិកម្មដើម្បីចាក់ផ្សាយស្តីពីពូជស្រូវកណ្តាលក្រអូប ផ្កាចន្ទសែនសរ របៀបប្រើជី NPK សម្រាប់ផលិតកម្មដំណាំស្រូវ បច្ចេកទេសផលិតជីកំប៉ុស្ដិ៍ និងថ្នាំកសិកម្មធម្មជាតិ និងបច្ចេកទេសដាំដំណាំប៉េងប៉ោះ
- ផ្សព្វផ្សាយពីបច្ចេកទេសកសិកម្មចំនួន ៩វីដេអូ និងឯកសារជាអត្ថបទបច្ចេកទេសកសិកម្មចំនួន ១៤ឯកសារ។

**១៦ ផ្នែកកសិ-ឧស្សាហកម្ម**

- ចូលរួមកិច្ចប្រជុំ និងពិភាក្សាលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការផ្តល់សិទ្ធិការពារដំណាំពូជថ្មីនៅកម្ពុជា

- ចុះគាំទ្រលើការអភិវឌ្ឍសមត្ថភាព គាំទ្រផ្នែកបច្ចេកទេស និងត្រួតពិនិត្យវាយតម្លៃលើការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិនៅច្រកចេញចូលតែមួយ

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីផែនការសកម្មភាព និងផែនការយុទ្ធសាស្ត្រប្រសិទ្ធភាពធនធាន និងផលិតកម្មស្អាតសម្រាប់វិស័យឧស្សាហកម្ម សហគ្រាសធុនតូច និងធុនមធ្យម២០២១-២០៣០ តាមប្រព័ន្ធ online

- ចូលរួមប្រជុំចង្អៀតស្តីពីការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ តាមប្រព័ន្ធ online

- ចូលរួមសិក្ខាសាលាស្តីពីបច្ចេកទេសត្រៀមសម្រាប់កម្មវិធីវាយតម្លៃទទួលស្គាល់អាជីវកម្មបរិយាប័ន្ននៅកម្ពុជាលើកទី១ តាមប្រព័ន្ធ online

- ចុះបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពបុគ្គលិកសិប្បកម្មកែច្នៃគ្រាប់ស្វាយចន្ទីជ័យសំបូរ អំពីប្រព័ន្ធគុណភាព និងសុវត្ថិភាព (HACCP) ប្រព័ន្ធគ្រប់គ្រងសរីរាង្គ និងត្រួតពិនិត្យលើផលិតកម្មសម្រាប់នាំចេញទៅកាន់ទីផ្សារប្រទេសជប៉ុនលើកទី៣។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចូលរួមកិច្ចប្រជុំរៀបចំផែនការមេទំនើបកម្មវិស័យកសិកម្មកម្ពុជា-ចិនតាម Zoom Meeting
- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីគំរូមិត្តកសិករតាម Zoom Meeting
- ទទួលទស្សនៈកិច្ចសិក្សារបស់មន្ត្រីមកពីអគ្គនាយកដ្ឋានកសិកម្មនៅទីវាលដើម្បីស្វែងយល់ពីផលិតកម្មគ្រាប់ពូជស្រូវ និងមន្ទីរពិសោធន៍នៅវិទ្យាស្ថាន
- ចុះត្រួតពិនិត្យការងារពិសោធន៍ និងបើកវគ្គបណ្តុះបណ្តាលកសិករនៅខេត្តព្រៃវែង និងខេត្តតាកែវ
- ចុះរៀបចំប្លង់ និងស្ទូងពិសោធន៍នៅខេត្តព្រៃវែង
- ចុះជ្រើសរើសទីកន្លែងពិសោធន៍នៅខេត្តតាកែវ
- ចុះត្រួតពិនិត្យការងារចម្ការពិសោធន៍បង្ហាញនៅខេត្តកំពង់ស្ពឺ។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- គ្រប់មហាវិទ្យាល័យ និងផ្នែកថ្នាក់ឆ្នាំសិក្សាមូលដ្ឋានបាននិងកំពុងដំណើរការបង្រៀននិស្សិតពីចម្ងាយតាមរយៈប្រព័ន្ធអេឡិចត្រូនិក និងតាម online សម្រាប់កម្មវិធីសិក្សាឆមាសទី២ ឆ្នាំសិក្សា២០២០-២០២១

- ចូលរួមជាវាគ្មិនពិសេសក្នុងវេទិកាស្តីពីតួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ និងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការអនុវត្តកសិកម្មសមស្របនៅខេត្តស្វាយរៀង ព្រៃវែង និងខេត្តត្បូងឃ្មុំ

- រៀបចំពិធីចែកកូនឈើ និងមាន់ពូជជូនប្រជាកសិករគោលដៅគម្រោងស៊ូប្រាក្នុងស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់ និងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

- រៀបចំកិច្ចប្រជុំពិភាក្សាស្តីពីការរៀបចំកិច្ចសហការណ៍រវាងគម្រោងលើកកម្ពស់គុណភាពឧត្តមសិក្សា (HEIP) និងគម្រោងលើកកម្ពស់គុណភាពមធ្យមសិក្សា (SEIP) និងការកសាងគម្រោងថ្មី (GEIP) ជាមួយសាកលវិទ្យាល័យដៃគូទាំង៥ និងនាយកដ្ឋានអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា

- សាស្ត្រាចារ្យ និងនិស្សិតបន្តការងារសិក្សាពិសោធន៍ស្រាវជ្រាវរបស់ខ្លួនលើប្រធានបទមួយចំនួនដូចជា ការពិ-សោធលើចំណីសត្វ ការចិញ្ចឹមសត្វ ការចាក់វ៉ាក់សាំង ពិសោធន៍លើអតិសុខុមប្រាណសាស្ត្រ បរាសិត ហើយនិស្សិតមួយចំនួនចុះហាត់ការងារផ្ទាល់នៅមន្ទីរពេទ្យសត្វនៃសាកលដោយថែទាំសត្វសម្រាកព្យាបាលនៅមន្ទីរពេទ្យ ធ្វើជំនួយការក្នុងការវះកាត់ គ្រៀវសត្វ និងថត X-ray សត្វ។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ១ ១២៧នាក់ (ស្រី៤៦៤នាក់) លើជំនាញ៖ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី

ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងសៀង និងភាសាអង់គ្លេស

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូសម្រាប់ការបណ្តុះបណ្តាលគម្រោងសិក្សាស្រាវជ្រាវសំខាន់ៗដែលកំពុងដំណើរការ គឺការពិសោធចិញ្ចឹមគោទឹកដោះ ការពិសោធចិញ្ចឹមបង្គា ការពិសោធបង្កាត់ពូជមាន់ ការសិក្សាពិសោធថ្នាំបណ្តេញសត្វល្អិត ការពិសោធចិញ្ចឹមពពែនៅតំបន់ភ្នំ ការសិក្សាស្រាវជ្រាវបង្កាត់គេសរកូល ការពិសោធដំណាំព្រីង ការសិក្សាពិសោធផលិតម្សៅឫស្សី ការបណ្តុះជាលិការុក្ខជាតិ ការពិសោធចិញ្ចឹមកង្កែប សាងសង់កសិដ្ឋានវារីសត្វ-រុក្ខជាតិ ការពិសោធចិញ្ចឹមត្រីបបែលនិងត្រីលម្អផ្សេងៗ ការសិក្សាផលិតកម្ម និងច្រវាក់តម្លៃស្វាយចន្ទី

- ចូលរួមសិក្ខាសាលាតាម Zoom meeting ស្តីពីគោលនយោបាយ និងកាលានុវត្តភាពផ្នែកហិរញ្ញប្បទានគម្រោងជីឧស្ម័ននៅប្រទេសកម្ពុជា

- ចូលរួមសិក្ខាសាលាតាម Zoom meeting ស្តីពីការផ្ទៀងផ្ទាត់លើរបាយការណ៍សិក្សាស្តីពីការវាយតម្លៃផលប៉ះពាល់សហគមន៍តាមដងទន្លេមេគង្គ និងទន្លេសាបដោយសារទឹកទន្លេមានកម្រិតទាបក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២០។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២០-២០២១ សរុបចំនួន ៦១០នាក់ (ស្រី២៧៤នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- ពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ប្រភពទឹកពីអាងចិញ្ចឹមត្រីនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ត្រួតពិនិត្យទូទៅការការពារ និងថែទាំចម្ការពិសោធន៍កូនកូនកៅស៊ូស៊ីដលីង និងច្បារបង្កាត់ពូជ

- ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យចម្ការពិសោធន៍កូន (ទិន្នផលជ័រ) សរុបចំនួន ១២ចម្ការពិសោធន៍

- ត្រួតពិនិត្យការថែទាំកូនកៅស៊ូដែលបំបៅរួចដើម្បីដាំពង្រីកនៅក្នុងច្បារពូជ

- ត្រួតពិនិត្យការចៀរជ័រ ការសាប្រមូលផលទឹកជ័រ និងស្រង់ទិន្នន័យជ័រកៅស៊ូតាមពិធីសាពិសោធន៍គ្រប់ចម្ការពិសោធន៍

- រៀបចំលាយថ្នាំរំញោច Ethephon តាមកំហាប់ខុសៗគ្នាដើម្បីលាបរំញោចតាមពិធីសាពិសោធន៍

- បណ្តុះបណ្តាលមន្ត្រីក្នុងការរៀបចំលាយសូលុយស្យុងវត្ថុធាតុគីមី និងវិភាគរកស្តង់ដារសរីរទឹកជ័រ (LD) លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose (Suc) និង Thiol (R-SH)

- បាញ់ថ្នាំការពារ និងព្យាបាលជំងឺផ្កាកុលាបលើកទី២ ប្លុក42DN 43AN និងប្លុក53DS

- ត្រួតពិនិត្យការងារបច្ចេកទេសចៀរជ័រ និងប្រមូលផលទឹកជ័រកៅស៊ូតាមរាននីមួយៗ

- វិភាគកៅស៊ូ RSS ចំនួន ៦សំណាកដើម្បីវាយតម្លៃគុណភាពនៃការកែច្នៃតាមស្តង់ដា CSR

- ចុះត្រួតពិនិត្យវាយតម្លៃរោងចក្រដើម្បីពង្រឹងការកែច្នៃ និងគុណភាពមន្ទីរពិសោធន៍មូលដ្ឋាន។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ២ ៦៨៧ ៣៨២ហ.ត ស្មើនឹង១០៣% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត និងការប្រមូលផលស្រូវស្រាលចំនួន ៣៤២ ២៥៧ហ.ត ដោយទទួលបរិមាណផលសរុប

ចំនួន ១ ៤២៨ ៨៥៥តោន លើសឆ្នាំមុនចំនួន ៦៨៨ ៥៤៨តោន និងទទួលទិន្នផលគិតជាមធ្យម ៤,១៧៥តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០២១
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង
- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន
- បន្តពង្រឹង និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វដល់កសិករ

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈ និងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត ជំងឺផ្តា-សាយបក្សី ជំងឺអាសន្នរោគ ជំងឺឆ្លង(ជំងឺចុងអង្គរ របេងជ្រូក គោ) បន្តតាមដានស្ថានភាពជំងឺស៊ូណូស និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

### ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

### ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

### ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញ

ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។

ថ្ងៃ ចន្ទ ១៤រោច ខែ ភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**